## ជំពូកទី៣
## ដំណើរការការងារ

**មាត្រា៤.-**

តាមការអញ្ជើញរបស់ប្រធាន សមាជិក និងអនុប្រធាន **គ.ហ.ស.** ត្រូវចូលរួមប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមាន ឬមានធុរៈ។

**មាត្រា៥.-**

**គ.ហ.ស.** មានសិទ្ធិអញ្ជើញមន្ត្រីផ្សេងទៀតនៃក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ចូលរួមប្រជុំ តាមការចាំបាច់។

**គ.ហ.ស.** មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងតំណាងសង្គមស៊ីវិល ចូលរួមប្រជុំក្នុងឋានៈជាសមាជិក ឬអ្នកសង្កេតការណ៍ តាមការចាំបាច់។

**មាត្រា៦.-**

**គ.ហ.ស.** មានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការ សម្រាប់បំពេញមុខងាររបស់ខ្លួន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន **គ.ហ.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។

**គ.ហ.ស.** ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងារ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា៧.-**

រចនាសម្ព័ន្ធរបស់ **គ.ហ.ស.**ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ៥៦ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួន រហូតដល់មានការរៀបចំថ្មីដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាប

ជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៤ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ.៤២.៣....អនក្រ.បក ចុះថ្ងៃទី.១៧ - ខែមករា - ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសរសេរជាអក្សរកាត់ថា “**អ.គ.ហ.**”។

**អ.គ.ហ.** បំពេញមុខងារជាលេខាធិការរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសរសេរជាអក្សរកាត់ថា **គ.ហ.ស.**។

**មាត្រា២.-**

**អ.គ.ហ.** មានទីតាំងស្ថិតនៅក្នុងទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងារ។

## ជំពូកទី២

## តួនាទី និងភារកិច្ច

**មាត្រា៣.-**

ក្នុងការបំពេញមុខងាររបស់ខ្លួន **អ.គ.ហ.** មានភារកិច្ចសម្របសម្រួលការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដូចតទៅ÷

- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ **គ.ហ.ស.** ស្របតាមការណែនាំ និងការសម្រេចរបស់ **គ.ហ.ស.** ដោយរួមទាំងការរៀបចំដាក់ឱ្យអនុវត្ត និងការតាមដានត្រួតពិនិត្យគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការរៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ
- សម្របសម្រួលប្រចាំថ្ងៃ លើការងាររដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ និងផ្នែកភស្តុភារក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ផ្តល់យោបល់ និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈម និងបញ្ហាជំនាញបច្ចេកទេសដើម្បីជំរុញល្បឿន និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សហការ និងសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំ និងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ផ្តល់ការគាំទ្រជូន អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពនានារបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ ដោយ

រាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស

- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាករកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន ដោយរាប់បញ្ចូលបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្គត់ផ្គង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ផ្សព្វផ្សាយ និងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

## ជំពូកទី៣
## រចនាសម្ព័ន្ធ

**មាត្រា៤.-**

**អ.គ.ហ.** ត្រូវដឹកនាំដោយអគ្គលេខាធិការ ១រូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងពីក្នុងចំណោមមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានគុណវុឌ្ឍិនិងបទពិសោធសមស្របតាមលក្ខខណ្ឌការងារតម្រូវ។

អគ្គលេខាធិការ ត្រូវតែងតាំងនិងបញ្ចប់តួនាទីដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធាន **គ.ហ.ស.**។

អគ្គលេខាធិការរង ត្រូវតែងតាំងនិងបញ្ចប់តួនាទីដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន **គ.ហ.ស.**។

**មាត្រា៥.-**

ការរៀបចំរចនាម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ **អ.គ.ហ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាប្រធាន **គ.ហ.ស.**។

**មាត្រា៦.-**

មន្ត្រីបម្រើការងារក្នុង **អ.គ.ហ.** ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងពីក្រសួង ស្ថាប័នដែលអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងករណីចាំបាច់ មន្ត្រីបម្រើការងារក្នុង **អ.គ.ហ.** អាចជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការនៃមុខងារសាធារណៈ ដោយផ្អែកលើគោលការណ៍សមត្ថភាព តម្លាភាព និងការប្រកួតប្រជែងបើកទូលាយ។

**មាត្រា៧.-**

លើកលែងអគ្គលេខាធិការនិងអគ្គលេខាធិការរង មន្ត្រីរាជការដែលត្រូវបានជ្រើសរើសឱ្យបម្រើការងារក្នុង **អ.គ.ហ.** ត្រូវបំពេញលក្ខខណ្ឌដូចតទៅ ÷

- ផ្អាកការងារនៅអង្គភាពដើមជាបណ្តោះអាសន្ន
- បំពេញការងារពេញម៉ោងនៅ **អ.គ.ហ.**

- រក្សាបាននូវប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ ប្រាក់ឧបត្ថម្ភផ្សេងៗ ក្នុងមុខងារសាធារណៈ អតីតភាពការងារ និងមុខតំណែងនៅអង្គភាពដើម ក្នុងពេលបំពេញមុខងារនៅ **អ.គ.ហ.**
- ទទួលបានការលើកទឹកចិត្ត ដោយទទួលបានមុខតំណែងសមស្រប នៅពេលវិលត្រឡប់ទៅបំពេញការងារនៅអង្គភាពដើមវិញ។

**មាត្រា៨.-**

ដោយមានការឯកភាពពីប្រធាន **គ.ហ.ស.** អគ្គលេខាធិការនៃ **អ.គ.ហ.** អាចជ្រើសរើសទីប្រឹក្សា អ្នកជំនាញការជាតិឬអន្តរជាតិ និងបុគ្គលិកជាប់កិច្ចសន្យាផ្សេងទៀត ដើម្បីជួយដល់ការងារ **អ.គ.ហ.**។

ការជ្រើសរើស ត្រូវអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៤
## កិច្ចដំណើរការនិងថវិកា

**មាត្រា៩.-**

**អ.គ.ហ.** មានកញ្ចប់ថវិកាផ្ទាល់ដោយឡែក សម្រាប់គាំទ្រកិច្ចដំណើរការរបស់ខ្លួន។

កញ្ចប់ថវិការបស់ **អ.គ.ហ.** មានប្រភពមកពី÷

- ថវិការដ្ឋដែលជាកញ្ចប់មួយនៅក្នុងថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងៗទៀត។

ថវិកាប្រចាំឆ្នាំរបស់ **អ.គ.ហ.** ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្អែកតាមសំណើរបស់អគ្គលេខាធិការនៃ **អ.គ.ហ.**។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា១០.-**

លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានបង្កើតឡើងដោយប្រកាសលេខ ១០០១ សហវ.ប្រក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ ត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួន រហូតដល់មានការរៀបចំ **អ.គ.ហ.** ស្របតាមខ្លឹមសារនៃអនុក្រឹត្យនេះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាប

ជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៤៤០,៣១ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ចេញពីដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៣១គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១១៤/០២០ ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៤
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៨៤៩អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១:** ត្រូវបានកាត់ដីទំហំ ៨៤០,៣១ ហិកតា ចេញពីដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០១១៤/០២០ ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៤ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៨២២ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ១៨,៣១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅភូមិពាមល្វា ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២:** ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៣១ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិពាមល្វា ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣:** ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ១.៦៤៩,១៧ ហិកតា នៅក្រុងសំរោង ខេត្តឧត្តរមានជ័យ ក្នុងនោះ កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងកាត់ចេញពីដីដែលមានដីកាដកហូត (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន គ្រីស្តាល់) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈបានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិត ២៥៥២ ខជ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- លិខិត ២៥៥០ ខជ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីសរុបទំហំ ១.៦៤៩,១៧ ហិកតា ក្នុងនោះ (១) ទំហំ ៤៧០,៧៥ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និង (២) ទំហំ ១.១៧៨,៤២ ហិកតា កាត់ចេញពីដីដែលមានដីកាដកហូត (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន គ្រីស្តាល់) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដែលទំហំ ១.៣៣៣,៦៣ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះដាក់ស្តែង និងទំហំ ៣១៥,៥៤ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិដងទង់ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ តាមប្រព័ន្ធភូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង នៅភូមិដងទង់ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៦១៧ ក្បាលដី ជូនប្រជាពលរដ្ឋ ៣៦៩ គ្រួសារ ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកាត់ដីសរុបទំហំ ១៦៤៩.១៧ ហិកតា នៅក្រុងសំរោង ខេត្តឧត្តរមានជ័យ ក្នុងនោះកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ កាត់ចេញពីដីដែលមានដីកាដកហូត អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន គ្រីស្តាល់ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី




Coordinate System UTM, Zone 48N Datum WGS 1984

| ID | POINT_X | POINT_Y | ID | POINT_X | POINT_Y |
|---|---|---|---|---|---|
| 1 | 371578 | 1585935 | 24 | 363888 | 1585464 |
| 2 | 371581 | 1585769 | 25 | 364180 | 1585685 |
| 3 | 371667 | 1585781 | 26 | 364196 | 1585770 |
| 4 | 371669 | 1585745 | 27 | 364148 | 1585873 |
| 5 | 371653 | 1585475 | 28 | 364267 | 1586090 |
| 6 | 371651 | 1585055 | 29 | 364092 | 1586143 |
| 7 | 371741 | 1584424 | 30 | 363995 | 1586113 |
| 8 | 371757 | 1584140 | 31 | 363935 | 1586176 |
| 9 | 371701 | 1584066 | 32 | 363866 | 1586223 |
| 10 | 371668 | 1583788 | 33 | 363930 | 1586270 |
| 11 | 371581 | 1583630 | 34 | 363870 | 1586482 |
| 12 | 365670 | 1583626 | 35 | 363735 | 1586412 |
| 13 | 365601 | 1583501 | 36 | 363760 | 1586763 |
| 14 | 365537 | 1583545 | 37 | 363776 | 1586816 |
| 15 | 365589 | 1583650 | 38 | 363799 | 1586843 |
| 16 | 365580 | 1585000 | 39 | 363811 | 1586897 |
| 17 | 364075 | 1585000 | 40 | 363799 | 1586951 |
| 18 | 364119 | 1585070 | 41 | 363910 | 1587051 |
| 19 | 364077 | 1585218 | 42 | 363864 | 1587084 |
| 20 | 364106 | 1585231 | 43 | 364615 | 1587168 |
| 21 | 364101 | 1585357 | 44 | 365444 | 1585862 |
| 22 | 364031 | 1585371 | 45 | 371578 | 1585935 |
| 23 | 363938 | 1585412 | | | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ២.៨០៧,៦៧ ហិកតា នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្នុងនោះ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ទីមរីង រ៉ាប់ប៊ើរ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន តៃនីញ សៀមរាបអភិវឌ្ឍន៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពី គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិត ១៦៩០ ឧជ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- លិខិត ២៣៧៣ ឧជ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីសរុបទំហំ ២.៨០៧,៦៧ ហិកតា ក្នុងនោះ (១) ទំហំ ១.២៥៥,០៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ទីមវីង វ៉ាប់ប៊េរ និង (២) ទំហំ ១.៥៥២,៦៤ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន តៃនីញ សៀមរាបអភិវឌ្ឍន៍ សម្រាប់ធ្វើប្រទានកម្មទំហំ ១.៧៣៤,៥៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១.០៧៣,១៣ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិខ្នងទូលមានជ័យ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង នៅភូមិខ្នងទូលមានជ័យ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ៥៥៨ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៥៥៦ ក្បាលដី ជូនប្រជាពលរដ្ឋ ៣៨៧ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសាធារណៈរបស់រដ្ឋ ២ ក្បាលដី (ដីសាលារៀន ០១ ក្បាលដី និងដីស្នាក់ការភូមិ ០១ ក្បាលដី) ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ(១)

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ២៥៧.អនក្រ.បក ចុះថ្ងៃទី២០........ខែ.កុម្ភៈ....ឆ្នាំ២០១៤ ស្តីពីការកាត់ដីសរុបទំហំ ២៨០៧.៦៧ ហិកតា នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្នុងនោះកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ទីមរីង រ៉ាប់ប៊ើរ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន តៃនីញ សៀមរាបអភិវឌ្ឍន៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី



ឧបសម្ព័ន្ធ(២)

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ..៧២-៦៨ អនក្រ.បក.....ចុះថ្ងៃទី..២០.........ខែ..មករា...ឆ្នាំ២០១៤ ស្តីពីការកាត់ដីសរុបទំហំ ២៨០៧,៦៧ ហិកតា នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្នុងនោះកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ទីមរីង វ៉ាប់បើរ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន តៃនីញ សៀមរាបអភិវឌ្ឍន៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

តារាងនិយាមការព្រំដីសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ

Coordinate System UTM, Zone 48N, Datum WGS 1984

| ID | X_Point | Y_Point | ID | X_Point | Y_Point | ID | X_Point | Y_Point |
|---|---|---|---|---|---|---|---|---|
| 1 | 414381 | 1565979 | 45 | 416204 | 1562008 | 89 | 410457 | 1565564 |
| 2 | 414343 | 1565809 | 46 | 416154 | 1562038 | 90 | 410492 | 1565522 |
| 3 | 414334 | 1565791 | 47 | 416087 | 1562041 | 91 | 410783 | 1565583 |
| 4 | 414422 | 1565625 | 48 | 416147 | 1562337 | 92 | 410893 | 1565607 |
| 5 | 414579 | 1565606 | 49 | 415845 | 1562260 | 93 | 411000 | 1565402 |
| 6 | 414583 | 1565679 | 50 | 415936 | 1562406 | 94 | 411364 | 1565569 |
| 7 | 414693 | 1565666 | 51 | 415808 | 1562376 | 95 | 411347 | 1565762 |
| 8 | 414781 | 1565586 | 52 | 415766 | 1562322 | 96 | 411637 | 1565949 |
| 9 | 415151 | 1565739 | 53 | 415590 | 1562321 | 97 | 411795 | 1565956 |
| 10 | 416365 | 1565936 | 54 | 415575 | 1562248 | 98 | 411904 | 1565979 |
| 11 | 416732 | 1565899 | 55 | 415408 | 1562307 | 99 | 411942 | 1565969 |
| 12 | 416819 | 1565870 | 56 | 415279 | 1562326 | 100 | 411960 | 1565969 |
| 13 | 417061 | 1565841 | 57 | 415050 | 1562243 | 101 | 412029 | 1565854 |
| 14 | 417405 | 1565709 | 58 | 415014 | 1562238 | 102 | 412258 | 1565939 |
| 15 | 417417 | 1565694 | 59 | 414961 | 1562371 | 103 | 412267 | 1566025 |
| 16 | 417445 | 1565584 | 60 | 414573 | 1562234 | 104 | 412373 | 1566052 |
| 17 | 417709 | 1565636 | 61 | 414539 | 1562230 | 105 | 412391 | 1565987 |
| 18 | 417584 | 1565508 | 62 | 414423 | 1562321 | 106 | 412517 | 1566002 |
| 19 | 417587 | 1565286 | 63 | 414278 | 1562219 | 107 | 412567 | 1565732 |
| 20 | 417606 | 1565275 | 64 | 414245 | 1562227 | 108 | 412543 | 1565690 |
| 21 | 417605 | 1565168 | 65 | 414185 | 1562264 | 109 | 412532 | 1565635 |
| 22 | 417681 | 1565065 | 66 | 413953 | 1562286 | 110 | 412586 | 1565623 |
| 23 | 417621 | 1564973 | 67 | 413983 | 1562322 | 111 | 412589 | 1565594 |
| 24 | 417715 | 1564964 | 68 | 413919 | 1562319 | 112 | 412800 | 1565619 |
| 25 | 417699 | 1564670 | 69 | 413815 | 1562294 | 113 | 412809 | 1565653 |
| 26 | 417620 | 1564704 | 70 | 413795 | 1562323 | 114 | 413056 | 1565619 |
| 27 | 417510 | 1564557 | 71 | 413590 | 1562323 | 115 | 413093 | 1565745 |
| 28 | 417504 | 1564506 | 72 | 413564 | 1562354 | 116 | 413177 | 1565869 |
| 29 | 417627 | 1564289 | 73 | 413569 | 1562285 | 117 | 413176 | 1565880 |
| 30 | 417600 | 1564026 | 74 | 413340 | 1562286 | 118 | 413290 | 1565840 |
| 31 | 417565 | 1563966 | 75 | 413330 | 1562232 | 119 | 413326 | 1565873 |
| 32 | 417549 | 1563906 | 76 | 413230 | 1562225 | 120 | 413334 | 1566000 |
| 33 | 417539 | 1563829 | 77 | 413215 | 1562085 | 121 | 413489 | 1565966 |
| 34 | 417544 | 1563729 | 78 | 413126 | 1562131 | 122 | 413483 | 1565955 |
| 35 | 417557 | 1563727 | 79 | 413098 | 1562145 | 123 | 413482 | 1565890 |
| 36 | 417562 | 1563459 | 80 | 412133 | 1562322 | 124 | 413553 | 1565825 |
| 37 | 417520 | 1563199 | 81 | 409998 | 1562322 | 125 | 413730 | 1566002 |
| 38 | 417554 | 1563191 | 82 | 409827 | 1562343 | 126 | 413858 | 1565971 |
| 39 | 417551 | 1562929 | 83 | 409579 | 1562344 | 127 | 414093 | 1566155 |
| 40 | 417478 | 1562809 | 84 | 409580 | 1565584 | 128 | 414196 | 1566316 |
| 41 | 417576 | 1562599 | 85 | 409835 | 1565576 | 129 | 414497 | 1566235 |
| 42 | 417576 | 1562285 | 86 | 409918 | 1565579 | 130 | 414411 | 1566125 |
| 43 | 417011 | 1562286 | 87 | 410116 | 1565596 | 131 | 414381 | 1565979 |
| 44 | 416256 | 1562016 | 88 | 410367 | 1565606 | | | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៧៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៣.០៧២,៥ ហិកតា នៅស្រុកសំឡូត ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន យូរីសាគរ និងកាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន តាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១០០៩ ខបប ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ១១៦៧ ខបប ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ៣.០៧២,៥ ហិកតា ក្នុងនោះ (១) ទំហំ ២.២៥២ ហិកតា ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន យូរីសាគរ និង (២) ទំហំ ៨២០,៥ ហិកតា កាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្ម ទំហំ ២.៨២៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២៤៥,៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅឃុំស៊ុង ស្រុកសំឡូត ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិ ដូចខាងក្រោម ៖

- កាត់ផ្ទៃដីទំហំ ២.៧១៩ ហិកតា ក្នុងនោះ (១) ទំហំ ១.៨៩៨,៥ ហិកតា ចេញពីដីព្រៃសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន យូរីសាគរ និង (២) ទំហំ ៨២០,៥ ហិកតា កាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្ម ទំហំ ២.៤៧៣,៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២៤៥,៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិកណ្តាល
- កាត់ផ្ទៃដីទំហំ ៣៥៣,៥ ហិកតា ចេញពីដីព្រៃសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន យូរីសាគរ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិស្រែរាជ

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិកណ្តាល និងភូមិស្រែរាជ ឃុំស៊ុង ស្រុកសំឡូត ខេត្តបាត់ដំបង ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ២.១៥៥ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២.១៥១ ក្បាលដី ជូនប្រជាពលរដ្ឋ ១.១៥៧ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៤ ក្បាលដី (ដីសាលារៀន ០២ ក្បាលដី និងដីបន្ទាយវរៈសេនាតូចលេខ ៥២២ ០២ ក្បាលដី) ដែលក្នុងនោះ ផ្តល់ជាកម្មសិទ្ធិលើក្បាលដី ៖

- សរុប ១.៧៨៨ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១.៧៨៥ ក្បាលដី ជូនប្រជាពលរដ្ឋ ៩៧២ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៣ ក្បាលដី (ដីសាលារៀន ០១ ក្បាលដី និងដីបន្ទាយវរៈសេនាតូចលេខ៥២២ ០២ ក្បាលដី) នៅភូមិកណ្តាល
- សរុប ៣៦៧ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៣៦៦ ក្បាលដី ជូនប្រជាពលរដ្ឋ ១៨៥ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (ដីសាលារៀន) នៅភូមិស្រែរាជ ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជនចំនួន ២០ រូប ដែលបានបះបង់កំលាំងកាយ ចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកជួយកសាង និងអភិវឌ្ឍន៍សមិទ្ធផលនានាលើគ្រប់វិស័យ ស្ថិតនៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

**ក. មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ០៥ គ្រឿង ផ្តល់ជូន :**

១-លោក **រុណ ពន្សុទិលិយ៉ា** នាយផ្នែកនាយកដ្ឋានរដ្ឋបាលសេនាធិការ
២-លោកស្រី **យិន សុម៉ូលីណា** សប្បុរសជននៅរាជធានីភ្នំពេញ
៣-លោក **គា ពិសិដ្ឋ** សប្បុរសជននៅរាជធានីភ្នំពេញ
៤-លោក **ម៉ិន ឆាន** សប្បុរសជននៅរាជធានីភ្នំពេញ
៥-លោក **សៅ គីមខ្សៀ** សប្បុរសជននៅខេត្តព្រៃវែង

**ខ. មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនាចំនួន ០៦ គ្រឿង ផ្តល់ជូន :**

១-លោក **រស់ សារ៉ាឌី** សប្បុរសជននៅរាជធានីភ្នំពេញ
២-លោកវរសេនីយ៍ទោ **ពៅ ជីទី** អត្តលេខ ០១២៩៨
៣-លោក **សៅ យានរិទ្ធីខុង** សប្បុរសជននៅរាជធានីភ្នំពេញ

៤-លោក **ជួប តត្តី** សប្បុរសជននៅរាជធានីភ្នំពេញ

៥-លោក **ម៉ែន រាហ៊ុល** សប្បុរសជននៅរាជធានីភ្នំពេញ

៦-លោក **ជួន ចិសាល** សប្បុរសជននៅខេត្តព្រៃវែង

**គ. មេដាយមុនីសារាភ័ណ្ឌថ្នាក់អស្សឫទ្ធិចំនួន ០៩ គ្រឿង ផ្ដល់ជូន :**

១-លោក **ប្រា សុផល** សប្បុរសជននៅខេត្តព្រៃវែង

២-លោក **ឈន់ ឆុន** សប្បុរសជននៅរាជធានីភ្នំពេញ

៣-លោក **អ៊ុំ ម៉ាសាឃុណា** សប្បុរសជននៅរាជធានីភ្នំពេញ

៤-លោក **នាង បញ្ញា** សប្បុរសជននៅរាជធានីភ្នំពេញ

៥-លោកអនុសេនីយ៍ឯក **អេង អ៊ុយឃាង** អត្តលេខ ០៩១២៦១មន្ត្រីក.ខ ហ.រកងពលតូចលេខ៧០

៦-លោកអនុសេនីយ៍ត្រី **ហ៊ុយ ធីតា** អត្តលេខ ៥៦៦៨៩

៧-លោកអនុសេនីយ៍ឯក **កយ សំណាង** អត្តលេខ ៣៨៨០០

៨-លោកអនុសេនីយ៍ទោ **សូ វណ្ណៈ** អត្តលេខ ៥៨៥២៧

៩-លោកអនុសេនីយ៍ត្រី **គង់ សុផាត** អត្តលេខ ៦៣៨២៧

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២ -រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេសចំនួន ០៩ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាង ព្រះវិហារ ជួសជុលសាលារៀន ផ្លូវលំ អណ្តូងទឹក និងបង្គន់អនាម័យ ស្ថិតនៅក្នុងឃុំអង្គរទ្រេត ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៤ គ្រឿង ផ្តល់ជូន :**

១-ឧបាសក **កែ សឺរត** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៣៩.៩៧៦ ដុល្លារ

២-លោក **ម៉ក់ អួន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២៦.៤០០ ដុល្លារ

៣-លោកស្រី **ឡេង សុខេម៉ានី** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២៦.១០០ ដុល្លារ

៤-ឯកឧត្តម **ចន្យ ទាសនា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.២៨០ ដុល្លារ

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០១ គ្រឿង ផ្តល់ជូន**

លោក **មាស គីមយ៉ាន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៥.០០០ ដុល្លារ

**គ. មេដាយសំរិទ្ធិស្ថាបនាជាតិចំនួន ០៤ គ្រឿង ផ្តល់ជូន :**

១-លោក **តឹក គីមឆួន** សប្បុរសជនខ្មែររស់នៅប្រទេសបារាំង ថវិកាចំនួន ៣.០០០ ដុល្លារ

២-លោក **ស៊ុន** **ឆូយ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៣.០០០ ដុល្លារ

៣-លោក **យី** **យ៉ន** សប្បុរសជននៅខេត្តកំពង់ចាម ថវិកាចំនួន ៣.០០០ ដុល្លារ

៤-លោក **ម៉ូ** **យ៉ុម** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ២.៤៥០ ដុល្លារ

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** ត្រូវបានដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ចំនួន ០៤ រូប ពីឋានន្តរស័ក្តិអនុមន្ត្រី ទៅឋានន្តរស័ក្តិវរមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងព័ត៌មាន ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ និងថ្នាក់ | |
|---|---|---|---|
| | | ចាស់ | ត្រូវដំឡើង |
| ១ | លោក **គ្រី ចំរើន** | ពីអនុមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ២ | លោក **ឈុន ម៉ិនសុខ** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៣ | លោកស្រី **នង រ័ត្នថា** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៤ | លោកស្រី **អ៊ុំ វណ្ណៈ** | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .-**

បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៅខេត្តពោធិ៍សាត់ចំនួន ៨៩ នាក់ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចបានល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

**ក- មេដាយមាសការងារ ៖**

១-លោក **ម៉ម ផាន់ណា** អនុប្រធានការិយាល័យសាលាខេត្តពោធិ៍សាត់
២-លោក **គង់ ខបុល** អភិបាលរងស្រុកបាកាន ខេត្តពោធិ៍សាត់
៣-លោក **ជៀម ពឿន** សមាជិកក្រុមប្រឹក្សាស្រុកបាកាន ខេត្តពោធិ៍សាត់
៤-លោក **សេ់ រឿន** សមាជិកក្រុមប្រឹក្សាស្រុកបាកាន ខេត្តពោធិ៍សាត់
៥-លោក **ម៉ែន រិទ្ធី** ប្រធានការិយាល័យសាលាស្រុកបាកាន ខេត្តពោធិ៍សាត់
៦-លោក **ផាយ ឡេខ** អភិបាលរងស្រុកកណ្តៀង ខេត្តពោធិ៍សាត់
៧-លោក **កែវ សារឿន** ស្មៀនឃុំស្វាយលួង ស្រុកបាកាន ខេត្តពោធិ៍សាត់
៨-លោក **ស ម្លែក** សមាជិកក្រុមប្រឹក្សាស្រុកក្រគរ ខេត្តពោធិ៍សាត់

៩-លោក **ឈាន ថាសនា** អភិបាលរងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់
១០-លោក **កែន កន** ទីប្រឹក្សាគ្រប់គ្រងកម្មវិធីស្រុកបាកាន ខេត្តពោធិ៍សាត់
១១-លោក **ហឿង ហុង** ទីប្រឹក្សាគ្រប់គ្រងកម្មវិធីស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់
១២-លោក **ជួប ឥមឡេង** ទីប្រឹក្សាគ្រប់គ្រងកម្មវិធីស្រុកកណ្ដៀង ខេត្តពោធិ៍សាត់
១៣-លោកស្រី **ម៉ុល ចណ្ណារ៉ា** ទីប្រឹក្សាគ្រប់គ្រងកម្មវិធីស្រុកក្រគរ ខេត្តពោធិ៍សាត់
១៤-លោក **គុំ ចាយ** ទីប្រឹក្សាគ្រប់គ្រងកម្មវិធីក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

**ខ- មេជាយប្រាក់ការងារ ៖**

១-លោកស្រី **គួយ ធារី** ប្រធានការិយាល័យសាលាខេត្តពោធិ៍សាត់
២-លោកស្រី **ឆួន ស៊ីណារ៉េត** អនុប្រធានការិយាល័យសាលាខេត្តពោធិ៍សាត់
៣-លោកស្រី **ម៉ុន បញ្ញារិទ្ធ** អនុប្រធានការិយាល័យសាលាខេត្តពោធិ៍សាត់
៤-លោកស្រី **មួង សុគន្ធា** អនុប្រធានការិយាល័យសាលាខេត្តពោធិ៍សាត់
៥-លោក **ចាប សោភ័ណ្ឌ** សមាជិកក្រុមប្រឹក្សាក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
៦-លោក **ឥម តារា** ប្រធាការិយាល័យសាលាក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
៧-លោក **ចក់ មល្លី** សមាជិកក្រុមប្រឹក្សាស្រុកបាកាន ខេត្តពោធិ៍សាត់
៨-លោក **កេត សាខុន** អនុប្រធានការិយាល័យសាលាស្រុកបាកាន ខេត្តពោធិ៍សាត់
៩-លោក **ខុន ស** ស្មៀនឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់
១០-លោក **នង ចំណាន** សមាជិកក្រុមប្រឹក្សាស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់
១១-លោក **នង ឡៃហៀម** សមាជិកក្រុមប្រឹក្សាស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់
១១-លោក **ឥម ទី** សមាជិកក្រុមប្រឹក្សាស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់
១២-លោក **ឈឺន លត** ស្មៀនឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់
១៣-លោក **ឃឹម បុត្ត** សមាជិកក្រុមប្រឹក្សាស្រុកក្រគរ ខេត្តពោធិ៍សាត់
១៤-លោក **ហាត្យ ឡាយ** សមាជិកក្រុមប្រឹក្សាស្រុកក្រគរ ខេត្តពោធិ៍សាត់
១៥-លោក **រ័ត្ន ហៃល** សមាជិកក្រុមប្រឹក្សាស្រុកក្រគរ ខេត្តពោធិ៍សាត់
១៦-លោកស្រី **ម៉ី សោភ័ណ្ឌា** សមាជិកក្រុមប្រឹក្សាស្រុកក្រគរ ខេត្តពោធិ៍សាត់
១៧-លោកស្រី **ឌុច ស្រីមុំ** អភិបាលរងស្រុកក្រគរ ខេត្តពោធិ៍សាត់
១៨-លោក **ម៉ិង តាំងឡាយ** នាយករដ្ឋបាលសាលាស្រុកក្រគរ ខេត្តពោធិ៍សាត់
២០-លោកស្រី **ឌុច សុខុម** សមាជិកក្រុមប្រឹក្សាស្រុកវាលវែង ខេត្តពោធិ៍សាត់

**គ- មេជាយសំរឹទ្ធការងារ ៖**

១-លោកស្រី **លឹម ម៉ុម** ប្រធានការិយាល័យសាលាខេត្តពោធិ៍សាត់
២-លោក **នែម លេងហៀង** អនុប្រធានការិយាល័យសាលាខេត្តពោធិ៍សាត់
៣-លោក **ឈាម គចឡុង** អនុប្រធានការិយាល័យសាលាខេត្តពោធិ៍សាត់
៤-លោក **នាយ ឥមម៉ុង** អនុប្រធានការិយាល័យសាលាខេត្តពោធិ៍សាត់
៥-លោក **សុខ តារ៉ារស្មី** អនុប្រធានការិយាល័យសាលាខេត្តពោធិ៍សាត់

| | |
|---|---|
| ៦-លោកស្រី **ម៉ក់ សុភាព** | មន្ត្រីសាលាខេត្តពោធិ៍សាត់ |
| ៧-លោកស្រី **សាន្ត ផាន់នី** | មន្ត្រីសាលាខេត្តពោធិ៍សាត់ |
| ៨-លោកស្រី **មៀច ពិសី** | មន្ត្រីសាលាខេត្តពោធិ៍សាត់ |
| ៩-លោកស្រី **ឃឹម សុខាវ៉ាថ** | មន្ត្រីសាលាខេត្តពោធិ៍សាត់ |
| ១០-លោក **ចាច កែវលក្ខណា** | អនុប្រធានការិយាល័យសាលាក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ |
| ១១-លោក **យ៉ិម យ៉ា** | មន្ត្រីសាលាក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ |
| ១២-លោក **គាត ឡុងឌី** | មន្ត្រីសាលាក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ |
| ១៣-លោកស្រី **ឃឹម សុជាត** | មន្ត្រីសាលាក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ |
| ១៤-លោក **ចេង ផល្លា** | មន្ត្រីសាលាក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ |
| ១៥-លោកស្រី **កែវ កក្កដា** | មន្ត្រីសាលាក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ |
| ១៦-លោក **ទ្រិក ពុទ្ធារិទ្ធ** | ស្មៀនសង្កាត់ស្វាយអាត់ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ |
| ១៧-លោក **ស្វាយ សំអឿន** | ប្រធានការិយាល័យសាលាស្រុកបាកាន ខេត្តពោធិ៍សាត់ |
| ១៨-លោកស្រី **ខៀវ រីឌី** | មន្ត្រីសាលាស្រុកបាកាន ខេត្តពោធិ៍សាត់ |
| ១៩-លោក **ខាន់ សៅ** | សមាជិកក្រុមប្រឹក្សាឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់ |
| ២០-លោក **ខៀវ ជន** | សមាជិកក្រុមប្រឹក្សាឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់ |
| ២១-លោក **ឆាយ ប៉ុច** | សមាជិកក្រុមប្រឹក្សាឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ |
| ២២-លោក **អ៊ុក សំយ៉ុល** | សមាជិកក្រុមប្រឹក្សាឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ |
| ២៣-លោក **ទូច សារឿន** | សមាជិកក្រុមប្រឹក្សាឃុំបឹងបត់កណ្តាល ស្រុកបាកាន |
| ២៤-លោក **សរ ភួន** | សមាជិកក្រុមប្រឹក្សាឃុំបឹងបត់កណ្តាល ស្រុកបាកាន |
| ២៥-លោក **គេង សុខន** | ជំទប់ទី២ឃុំស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់ |
| ២៦-លោក **ឌុក ឃន** | សមាជិកក្រុមប្រឹក្សាឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់ |
| ២៧-លោក **ពាង ឃន** | សមាជិកក្រុមប្រឹក្សាឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់ |
| ២៨-លោក **មឿន មុត** | សមាជិកក្រុមប្រឹក្សាឃុំត្រពាំងជង ស្រុកបាកាន |
| ២៩-លោក **ឆេង ជឿន** | អនុប្រធានការិយាល័យសាលាស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ |
| ៣០-លោក **គ ហ៊ួ** | មន្ត្រីសាលាស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ |
| ៣១-លោក **អ៊ុំ សាមិ** | មេឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ |
| ៣២-លោក **ឃិន ណារ** | សមាជិកក្រុមប្រឹក្សាឃុំផ្ទះរុង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ |
| ៣៣-លោក **ខួត ខាន** | សមាជិកក្រុមប្រឹក្សាឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ |
| ៣៤-លោក **ឆយ ចាន់ណា** | ស្មៀនឃុំរកាត ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ |
| ៣៥-លោក **ឌី ស៊ីណួត** | ស្មៀនឃុំផ្ទះរុង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ |
| ៣៦-លោក **គុល សុភក្ត** | ប្រធានការិយាល័យសាលាស្រុកកណ្តៀង ខេត្តពោធិ៍សាត់ |
| ៣៧-លោក **ញ៉ុក ឆៀង** | ជំទប់ទី១ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ |
| ៣៨-លោក **ម៉ើ កែ** | សមាជិកក្រុមប្រឹក្សាស្រុកក្រគរ ខេត្តពោធិ៍សាត់ |
| ៣៩-លោក **មិន ឌួង** | សមាជិកក្រុមប្រឹក្សាស្រុកក្រគរ ខេត្តពោធិ៍សាត់ |

| | |
|---|---|
| ៤០-លោក **ថៃ លាង** | សមាជិកក្រុមប្រឹក្សាស្រុកក្រគរ ខេត្តពោធិ៍សាត់ |
| ៤១-លោក **ឡាក់ ចាន់សំអាត** | សមាជិកក្រុមប្រឹក្សាស្រុកក្រគរ ខេត្តពោធិ៍សាត់ |
| ៤២-លោកស្រី **គួក ហុន** | សមាជិកក្រុមប្រឹក្សាស្រុកក្រគរ ខេត្តពោធិ៍សាត់ |
| ៤៣-លោកស្រី **ឌឹម សៅដា** | សមាជិកក្រុមប្រឹក្សាស្រុកក្រគរ ខេត្តពោធិ៍សាត់ |
| ៤៤-លោកស្រី **ណាំ សុដា** | ស្មៀនឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ |
| ៤៥-លោក **ជា យ៉ុង** | ស្មៀនឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ |
| ៤៦-លោក **ញ៉ែម ហឿង** | អនុប្រធានការិយាល័យសាលាស្រុកក្រគរ ខេត្តពោធិ៍សាត់ |
| ៤៧-លោក **ម៉ែត ចាន់ណា** | ស្មៀនឃុំឈើតុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ |
| ៤៨-លោក **គ្រួច សន្តិភាព** | ស្មៀនឃុំស្វាយស ស្រុកក្រគរ ខេត្តពោធិ៍សាត់ |
| ៤៩-លោក **ញ៉ែម ផុត** | ស្មៀនឃុំកំពង់ពោធិ៍ ស្រុកក្រគរ ខេត្តពោធិ៍សាត់ |
| ៥០-លោក **ខឡូ អេង** | នាយករងរដ្ឋបាលសាលាស្រុកវាលវែង ខេត្តពោធិ៍សាត់ |
| ៥១-លោក **គុល សុផល** | ប្រធានការិយាល័យសាលាស្រុកវាលវែង ខេត្តពោធិ៍សាត់ |
| ៥២-លោក **ប្រាក់ រតនា** | មន្ត្រីសាលាស្រុកវាលវែង ខេត្តពោធិ៍សាត់ |
| ៥៣-លោក **ឆួច ឈុំ** | ជំទប់ទី១ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ |
| ៥៤-លោក **ម៉ែន សុវណ្ណី** | អនុប្រធានការិយាល័យ នៃពន្ធនាគារខេត្តពោធិ៍សាត់ |
- រៀបចំផែនការមេ (Master Plan) សំរាប់អនុវត្តផែនការដោះស្រាយផលប៉ះពាល់ដោយសារគម្រោង មុននឹងគម្រោងចាប់ផ្តើមដំណើរការ
- ពិនិត្យ និងផ្តល់យោបល់លើសៀវភៅផែនការសកម្មភាពសម្រាប់ការដោះស្រាយផលប៉ះពាល់នៃគម្រោងនិមួយៗ (Resettlement Action Plan, RAP) តាមការណែនាំពីថ្នាក់ដឹកនាំនាយកដ្ឋានដើម្បីជូនថ្នាក់ដឹកនាំក្រសួងជ្រាប និងផ្តល់ការណែនាំបន្ថែម

- ពិនិត្យលម្អិតលើឯកសារគោលនយោបាយស្តីពីសិទ្ធិទទួលបានប្រាក់សំណង (Entitlement Matrix) សម្រាប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងនិមួយៗ ដែលបានឯកភាពដោយរាជរដ្ឋាភិបាល និងណែនាំដល់មន្ត្រីទទួលបន្ទុកដើម្បីអនុវត្តបន្តនៅទីវាល
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការអង្កេតវាស់វែងលម្អិត (Detailed Measurement Survey, DMS) នៃគម្រោងនិមួយៗ បន្ទាប់ពីការបញ្ចប់ការវាស់វែងលម្អិត
- រៀបចំការប្រជុំសម្របសម្រួលការងារជាមួយមន្ត្រីនៃក្រសួង- ស្ថាប័នពាក់ព័ន្ធដែលជាសមាជិកក្រុមការងារគណៈកម្មការអន្តរក្រសួងនៅទីតាំងគម្រោង ដើម្បីជំរុញការអនុវត្តការងារដោះស្រាយផលប៉ះពាល់
- រៀបចំអោយមានរបាយការណ៍ជាប្រចាំខែស្តីពីវឌ្ឍនាការនៃការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងជូនថ្នាក់ដឹកនាំនាយកដ្ឋាន និងឯកឧត្តមប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីជ្រាប និងសុំការណែនាំបន្ថែម ក្នុងករណីមានបញ្ហាមិនអាចដោះស្រាយបាន ត្រូវលើកសំណូមពរជូនថ្នាក់ដឹកនាំក្រសួង ដើម្បីពិភាក្សារកដំណោះស្រាយ និងសម្រេច
- រៀបចំរបាយការណ៍បញ្ចប់ស្តីពីការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោង ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការងារដោះស្រាយផលប៉ះពាល់ត្រូវបានបញ្ចប់ជាស្ថាពរ
- រៀបចំលិខិតប្រគល់ទីតាំងគម្រោងទៅអង្គភាព/ស្ថាប័នអនុវត្តន៍គម្រោង បន្ទាប់ពីការងារដោះស្រាយផលប៉ះពាល់ត្រូវបានបញ្ចប់
- បំពេញភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន ។

### ៣. ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង

ការិយាល័យនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- ជាសេនាធិការឱ្យប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់លើបេសកកម្មត្រួតពិនិត្យអនុលោមភាពនៃការអនុវត្តការងារដោះស្រាយផលប៉ះពាល់ចាប់តាំងពីដំណាក់កាលវាស់វែងលម្អិតរហូតដល់ដំណាក់កាលផ្តល់ប្រាក់សំណងជូនប្រជាពលរដ្ឋរងផលប៉ះពាល់
- ពិនិត្យឯកសារគោលការណ៍ និងគោលនយោបាយដោះស្រាយផលប៉ះពាល់នៃសៀវភៅផែនការសកម្មភាពនៃការដោះស្រាយផលប៉ះពាល់សម្រាប់គ្រប់គម្រោងដែលបានទទួលការឯកភាពពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍
- ពិនិត្យទិន្នន័យផលប៉ះពាល់ទ្រព្យសម្បត្តិនៃការវាស់វែងលម្អិតនៅតាមគម្រោងនិមួយៗដែលបានមកពីការិយាល័យដោះស្រាយផលប៉ះពាល់ទាំង ០៣ ខាងលើ

Sok

- ផ្ទៀងផ្ទាត់សំណើដកសាច់ប្រាក់សម្រាប់ផ្តល់សំណងគោលនយោបាយជូនប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោងរបស់អនុគណៈកម្មការខេត្តជាមួយទិន្នន័យផលប៉ះពាល់ទ្រព្យសម្បត្តិនៃការវាស់វែងលម្អិតមុននឹងបញ្ចេញថវិកា
- សហការជាមួយការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្នុងការផ្ទៀងផ្ទាត់លទ្ធផលនៃការសិក្សាតម្លៃជំនួសឱ្យមានសង្គតភាពនឹងស្ថានភាពជាក់ស្តែងនៃតំបន់គម្រោងមុនការផ្តល់យោបល់ឬអនុសាសន៍ជូននាយកដ្ឋាន
- ចុះពិនិត្យតាមភាពចាំបាច់នូវសកម្មភាពបើកផ្តល់ប្រាក់សំណងគោលនយោបាយជូនប្រជាពលរដ្ឋរងផលប៉ះពាល់នៅទីតាំងនៃគម្រោង
និងផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃចំនួនទឹកប្រាក់ដែលផ្តល់ជូនប្រជាពលរដ្ឋ រងផលប៉ះពាល់
- ធ្វើរបាយការណ៍ស្តីពីស្ថានភាព និងលទ្ធផលនៃការត្រួតពិនិត្យអនុលោមភាពនៃការអនុវត្តការងារដោះស្រាយផលប៉ះពាល់ និងការងារបើកផ្តល់ប្រាក់សំណងគោលនយោបាយ ជូនប្រធាននាយកដ្ឋាន បន្ទាប់ការបើកផ្តល់ប្រាក់សំណងគោលនយោបាយត្រូវបានបញ្ចប់
- រៀបចំផែនការត្រួតពិនិត្យប្រចាំឆ្នាំលើការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងនិមួយៗ ប៉ុន្តែក្នុងករណីចាំបាច់ ត្រូវចុះត្រួតពិនិត្យតាមការចាត់តាំងរបស់ប្រធាននាយកដ្ឋាន
- សម្របសម្រួលយន្តការដោះស្រាយបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ ដោយរៀបចំលិខិតឆ្លើយតបទៅប្រជាពលរដ្ឋសម្រាប់កម្រិតឃុំ/សង្កាត់ និងស្រុក/ខណ្ឌ ។
- រៀបចំកញ្ចប់ថវិកាប៉ាន់ស្មានសម្រាប់ដំណើរការយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងការអនុវត្តនីតិវិធីជំនាញស្របតាមគោលនយោបាយដោះស្រាយផលប៉ះពាល់របស់ដៃគូអភិវឌ្ឍន៍
- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទាំងនៅការិយាល័យនិងនៅតំបន់គម្រោង ដោយធ្វើការផ្តល់យោបល់កែលម្អ និងដោះស្រាយរាល់បញ្ហាឱ្យបានសមស្រប
- បំពេញភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន ។

**ប្រការ ៣ ÷** ភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់នាយកដ្ឋាន ឬអង្គភាពជំនាញដ៏ទៃទៀត ប្រធាននាយកដ្ឋាន ត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធនោះ សុំការណែនាំ ឬសុំគោលការណ៍ពីថ្នាក់ដឹកនាំក្រសួងដើម្បីរួមគ្នាដោះស្រាយ។

**ប្រការ ៤ ÷** ប្រកាសលេខ ២៩៣ សហវ.ប្រក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥ ÷** អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ និងគ្រប់នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត និងសហការតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០១៣

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ពន្លឺ មុនីរ័ត្ន**

**<u>ចម្លងជូន៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការមុខងារសាធារណៈ
- ក្រសួង និងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ ១ និងប្រការ ២
  "ដើម្បីអនុវត្ត"
- ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**អគ្គលេខាធិការដ្ឋាន**

**រចនាសម្ព័ន្ធនៃនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ១២១២ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

# ប្រកាសណែនាំ
# ស្តីពី
# ការបិទបញ្ជីចំណូល-ចំណាយ និង
# ការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៣

- យោងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- យោងព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- យោងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង-ខេត្ត-ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញនិងអង្គការសាធារណៈរដ្ឋបាល
- យោងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- យោងអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- យោងអនុក្រឹត្យលេខ ២៧៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- យោងប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- យោងប្រកាសលេខ ៣៦៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១១ ស្តីពីការបង្កើតបន្ថែមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាថ្នាក់ជាតិ

'លេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
)2, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ដោយការិយបរិច្ឆេទនៃឆ្នាំថវិកាត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ (មាត្រា ១១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ)ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំអំពីនីតិវិធីបច្ចេកទេស ដើម្បីធានាឱ្យការបិទបញ្ជីចំណូល-ចំណាយនិងការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិ ឆ្នាំ២០១៣ ប្រព្រឹត្តទៅបានត្រឹមត្រូវនិងទាន់ពេលវេលាដូចតទៅនេះ៖

## I- អំពីការបិទបញ្ជីចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៣

### ក-អំពីចំណូលថវិកាថ្នាក់ជាតិ

ចំណូលថវិកាទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយឬមួយពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ (ភាគទីIII និងមាត្រា១០៦ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ )។ ដូចនេះប្រាក់**ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៣ ជាកំហិត។**

### ខ-អំពីចំណាយថវិកាថ្នាក់ជាតិ

ការបិទបញ្ជីចំណាយ (មាត្រា១០៧ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥) ត្រូវដំណើរការទៅតាមដំណាក់កាលចំណាយនិងពេលវេលាដូចតទៅ ៖

- ទិដ្ឋាការនៃការសន្យាចំណាយក្រៅពីចំណាយបៀវត្ស និងចំណាយសម្រាប់គោលនយោបាយសង្គមកិច្ច មិនអាចអនុវត្តក្រោយថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ បានទេ (មាត្រា១០៨ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥) លើកលែងក្នុងករណីមានចំណាយចាំបាច់មិនអាចខានបាននិងមានឥណទានថវិកាសល់ទំនេរ ហើយទិដ្ឋាការនេះត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(មាត្រា២០ នៃអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៥)តែក៏មិនឱ្យហួសពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ ដែរ។
- រាល់ការសន្យាចំណាយដែលអាណត្តិបើកប្រាក់មិនបានប្រតិបត្តិការនៅមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ត្រូវបានបដិសេធចោលហើយត្រូវស្នើសុំធានាចំណាយជាថ្មី ដោយប្រើប្រាស់ឥណទានថវិកានៃឆ្នាំបន្ទាប់(មាត្រា ១០៩ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥)។
- រតនាគារថ្នាក់កណ្តាលនិងរតនាគារថ្នាក់មូលដ្ឋាន ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់ត្រឹមវេលាម៉ោង ១៧ និង ៣០ នាទី នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។ ដូច្នេះក្រសួងស្ថាប័នត្រូវប្រមូលសក្ខីប័ត្រនិងលិខិតយុត្តិការដែលបញ្ជាក់ពីសេវាដែលបានធ្វើរួច ដើម្បីរៀបចំអាណត្តិបើកប្រាក់ហើយបញ្ជូនទៅឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣។

### គ-អំពីចំណាយរដ្ឋទេយ្យបុរេប្រទាននិងថវិកាបុរេប្រទាន

- រដ្ឋទេយ្យករបុរេប្រទាន ត្រូវប្រមែប្រមូលលិខិតយុត្តិការចំណាយដើម្បីធ្វើអាណត្តិនិយ័តកម្ម(ទូទាត់) យ៉ាងយូរបំផុតក្នុងរយៈពេលមួយខែ ដោយគិតចាប់ពីកាលបរិច្ឆេទដកសាច់ប្រាក់ពីរតនាគារថ្នាក់កណ្តាលឬរតនាគារថ្នាក់មូលដ្ឋាន(មាត្រា៦៧ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥) លើកលែងតែក្នុង

ខែធ្នូនៃឆ្នាំ រតនាគារថ្នាក់កណ្តាលនិងរតនាគារថ្នាក់មូលដ្ឋានត្រូវបញ្ឈប់ការដកសាច់ប្រាក់រង្វាន់ទេយ្យបុរេប្រទានចុងក្រោយបង្អស់នៅម៉ោង ១៧ និង ៣០នាទី នាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣។ ក្នុងរយៈពេលពីថ្ងៃទី១៣ ដល់ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ រង្វាន់ទេយ្យករបុរេប្រទានត្រូវតែប្រមូលឯកសារនិងលិខិតយុត្តិការចំណាយរួចធ្វើអាណត្តិនិយ័តកម្មឆ្លងទិដ្ឋាការរួចបញ្ជូនទៅរតនាគារថ្នាក់កណ្តាល ឬរតនាគារថ្នាក់មូលដ្ឋានយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ជាកំហិត។ ចំពោះសាច់ប្រាក់រង្វាន់ទេយ្យបុរេប្រទានដែលក្រសួងស្ថាប័ន មន្ទីរ អង្គភាពចំណាយសល់ត្រូវយកមកបង់នៅរតនាគារថ្នាក់កណ្តាលឬរតនាគារថ្នាក់មូលដ្ឋានឱ្យបានមុនថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣។

- ថវិកាបុរេប្រទានគឺជាការបើកផ្តល់ចំណាយមុននៅក្នុងករណីមានការចាំបាច់បន្ទាន់។ ដូច្នេះការផ្តល់ថវិកាបុរេប្រទានត្រូវបញ្ឈប់នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ហើយការទូទាត់ថវិកាបុរេប្រទាននេះ ក៏ត្រូវតែប្រមូលឯកសារសុំទូទាត់ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។ ក្នុងករណីប្រាក់បុរេប្រទានឆ្នាំ២០១៣ ដែលមិនបានធ្វើការទូទាត់ឱ្យអស់នោះទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងកាត់ទុកឥណទានថវិកាពាក់ព័ន្ធក្នុងក្របខ័ណ្ឌថវិកាឆ្នាំ ២០១៤ មុននឹងធ្វើការធានាចំណាយសម្រាប់ឆ្នាំ២០១៤។

- ការទូទាត់ថ្លៃសេវាប្រើប្រាស់រថយន្តប្រណិតជូនក្រុមហ៊ុន LIMOUSINE ក្រសួងស្ថាប័នសាមីត្រូវតែបោះផ្សាយអាណត្តិនិយ័តកម្មឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៣។ ក្នុងករណីមានការខ្វះខាតឥណទានថវិកាសម្រាប់ធ្វើការទូទាត់រង្វាន់ទេយ្យបុរេប្រទានឬបុរេប្រទាន រង្វាន់ទេយ្យករត្រូវរាយការណ៍ជាបន្ទាន់ទៅអាណាប័កដើម្បីមានវិធានការតាមការជាក់ស្តែង ជាអាទិ៍ ៖

  - លើកសំណើសុំធ្វើនិយ័តភាពថវិកាផ្ទៃក្នុងដែលសល់ទំនេរ មកបំពេញឱ្យខ្ទង់ថវិកាដែលត្រូវធ្វើអាណត្តិនិយ័តកម្ម ក្នុងនោះគិតរួមទាំងប្រាក់បុរេប្រទានឆ្នាំមុនៗផងដែរ ។
  - កាត់បន្ថយឬផ្អាកជាបណ្តោះអាសន្ននូវទឹកប្រាក់បានធានាចំណាយមួយចំនួនដែលមិនសូវចាំបាច់ សំដៅធ្វើការជម្រះបញ្ជីចំណាយថវិការង្វាន់ទេយ្យបុរេប្រទានឬបុរេប្រទានឱ្យបានជ្រះស្រឡះ។

### ឃ-អំពីចលនាឥណទាន

ការធ្វើនិយ័តភាពថវិកា សម្រាប់ការទូទាត់ចំណាយចាំបាច់ ឬទូទាត់រង្វាន់ទេយ្យបុរេប្រទាន ឬទូទាត់បុរេប្រទានត្រូវបញ្ឈប់នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣។ ដូច្នេះក្រសួងស្ថាប័ននិងមន្ទីរជំនាញតាមរាជធានី ខេត្តទាំងអស់ត្រូវបញ្ជូនសំណុំលិខិតស្នើសុំនិយ័តភាពឥណទានមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣។

### ង-កិច្ចប្រតិបត្តិការនិយ័តកម្មនៃរតនាគារ

កិច្ចប្រតិបត្តិការនិយ័តកម្មនៃរតនាគារសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ត្រូវបន្តរហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ (មាត្រា១១ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥)។ កិច្ចប្រតិបត្តិការនេះត្រូវពិនិត្យកត់ត្រាជាលេខនាបន្ថែមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ដែលទាក់ទងទៅនឹង ៖

- ការកត់ត្រាជាស្ថាពរនៃចំណូល ឬចំណាយដែលបានពិនិត្យកត់ត្រាជាលេខនាមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ជាអាទិ៍ចូលគណនីកត់ត្រាបណ្តោះអាសន្ន។

- អាណត្តិនិយ័តកម្មដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរដ្ឋទេយ្យបុរេប្រទាន និងបុរេប្រទានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។
- ការកែតម្រូវលេខនាខុស
- កិច្ចប្រតិបត្តិការប្រមូលកិច្ចការពីគណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ និងគណនេយ្យកររងនៃរតនាគារថ្នាក់មូលដ្ឋាន។

**ច-កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០១៤**

១-អនុញ្ញាតឱ្យក្រសួងស្ថាប័នរៀបគម្រោងនិងស្នើសុំជានាចំណាយថវិកាសម្រាប់ឆ្នាំ២០១៤ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលានាចុងខែធ្នូឆ្នាំ២០១៣។ ថវិកាស្នើសុំជានាចំណាយត្រូវឈរលើមូលដ្ឋាន ៥០% នៃកញ្ចប់ថវិកាឆ្នាំ២០១៤ ដែលបានពិភាក្សានិងបានឯកភាពជាគោលការណ៍ក្នុងពេលការពារថវិកានៅគណៈរដ្ឋមន្ត្រីលើកលែងតែក្រសួងស្ថាប័នមួយចំនួនដែលអនុញ្ញាតឱ្យស្នើសុំជានាចំណាយ១០០%នៃកញ្ចប់ថវិកាឆ្នាំ ២០១៤ លើមុខចំណាយខ្លះក្នុងនោះមាន៖ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សម្រាប់ទិញអង្ករនិងឯកសណ្ឋាន ក្រសួងសុខាភិបាលសម្រាប់ការទិញឱសថនិងបរិក្ខារពេទ្យ ក្រសួងអប់រំ យុវជននិងកីឡា សម្រាប់ការបោះសៀវភៅគោលនិងកម្មសិទ្ធិបញ្ញា។

២-គម្រោងស្នើសុំជានាចំណាយត្រូវធ្វើឡើងចំពោះតែមុខចំណាយសម្រាប់ទំនិញ បរិក្ខារ សេវា ឬការជួសជុលថែទាំទាំងឡាយណាដែលមានរយៈពេលវែងក្នុងការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។

៣-ពេលទទួលបានលិខិតជានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមដំណើរការឱ្យបានរួសរាន់នូវកិច្ចលទ្ធកម្មសាធារណៈ ដើម្បីឱ្យសាមីក្រសួងស្ថាប័នទទួលបានទំនិញ សេវា ឬការជួសជុលថែទាំមកប្រើប្រាស់តាមការគ្រោងទុក។

៤- ចំពោះការទូទាត់ត្រូវធ្វើឡើងជាដំណាក់កាលៗទៅតាមត្រីមាស ក្រោយពីមានការប្រគល់ទទួលទំនិញ សេវាជាក់ស្តែងដោយជៀសវាងនូវការទូទាត់ដែលធ្វើឡើងជាគំហុកតែម្តងនៅពេលវេលាណាមួយ។

៥- ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ តទៅរាល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំថ្មីត្រូវកត់ត្រាចូលក្នុងគណនីថវិកាថ្នាក់ជាតិឆ្នាំ២០១៤។ ចំពោះចំណាយប្រាក់បៀវត្ស(ជំពូក៦៤) និងចំណាយនៃជំពូកផ្សេងៗទៀតដែលនៅសល់ក្នុងឆ្នាំ២០១៣ ហើយយកមកបង់ចូលក្នុងឆ្នាំ២០១៣ ត្រូវកត់ត្រាចូលត្រង់ទៅផ្នែកខាងឥណទាននៃគណនីនិងអនុគណនីចំណាយថវិកាដែលពាក់ព័ន្ធ។ ដោយឡែកការបង់សំណេះចំណាយក្រោយថ្ងៃទី ៣១ ខែធ្នូ នៃការិយបរិច្ឆេទត្រូវចាត់ទុកជាចំណូលថវិកាផ្សេងៗនៃការិយបរិច្ឆេទសម្រាប់ឆ្នាំថ្មីគឺត្រូវកត់ត្រាខាងឥណទាននៃគណនី៧៦៨ "ផលហិរញ្ញវត្ថុផ្សេងៗ"។

៦- រាល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៤ ត្រូវផ្អែកលើកម្មវិធីចំណូល-ចំណាយប្រចាំខែនិងត្រីមាសដែលក្រសួងស្ថាប័នរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានីខេត្តត្រូវរៀបចំនិងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា -នាយកដ្ឋានថវិកានីយកម្ម) ក្នុងរយៈពេល០២សប្តាហ៍ក្រោយពីច្បាប់ថវិកាត្រូវបានអនុម័ត។

**II.ការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៣**

ការបូកសរុបការអនុវត្តថវិកាថ្នាក់ជាតិឆ្នាំ២០១៣ ត្រូវដំណើរការដូចតទៅ ៖

- ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៤ អគ្គនាយកដ្ឋានរតនាគារជាតិត្រូវដំណើរការបូកសរុបកិច្ចប្រតិបត្តិការរតនាគារទូទាំងប្រទេសអំពីការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៣ ព្រមទាំងតារាងតុល្យភាពគណនីជាស្ថាពរហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា-នាយកដ្ឋានថវិកានីយកម្ម) យ៉ាងយូរត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤។

- ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ គ្រប់មន្ទីរជំនាញរាជធានីខេត្ត ត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខអនុវត្តចំណូល-ចំណាយរបស់អង្គភាពខ្លួនឱ្យបានត្រូវគ្នាជាមួយរតនាគារនិងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយរៀបចំរបាយការណ៍បូកសរុបអនុវត្តថវិការបស់ខ្លួនរួចផ្ញើមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងសាមីចំនួន ០២ ច្បាប់ឱ្យបានមុនថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤។

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានភារកិច្ចបូកសរុបការអនុវត្តចំណូល-ចំណាយរបស់មន្ទីរជំនាញរាជធានី ខេត្ត ដែលបានផ្ទៀងផ្ទាត់ រួចផ្ញើមកអគ្គនាយកដ្ឋានថវិកា(នាយកដ្ឋានថវិកានីយកម្ម) ឱ្យបានមុនថ្ងៃទី៣១ ខែមករា ឆ្នាំ ២០១៤ ជាកំហិត។

រតនាគាររាជធានីខេត្តមានភារកិច្ចបូកសរុបការអនុវត្តចំណូល-ចំណាយរបស់មន្ទីរជំនាញរាជធានី ខេត្ត ដែលបានផ្ទៀងផ្ទាត់ រួចផ្ញើមកអគ្គនាយកដ្ឋានរតនាគារជាតិ ឱ្យបានមុនថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ជាកំហិត។

ចំពោះក្រសួងស្ថាប័នរដ្ឋបាលកណ្ដាល ត្រូវផ្ទៀងផ្ទាត់តួលេខចំណូល-ចំណាយថវិការបស់ខ្លួនជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ (ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស) និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីឱ្យបានត្រូវគ្នាហើយរៀបចំរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិការបស់ស្ថាប័នខ្លួន ដោយមានបញ្ចូលចំណូល-ចំណាយថវិការបស់មន្ទីរជំនាញនានាក្រោមឱវាទនៅតាមរាជធានីខេត្តផង រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិនិងអគ្គនាយកដ្ឋានថវិកា-នាយកដ្ឋានថវិកានីយកម្ម) ឱ្យបានមុនថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ជាកំហិត។

ចំពោះចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស ក្រសួងស្ថាប័នត្រូវផ្ទៀងផ្ទាត់តួលេខអនុវត្តជាមួយអង្គភាពគ្រប់គ្រងគម្រោងរបស់ស្ថាប័ននីមួយៗ ហើយរៀបចំរបាយការណ៍បូកសរុបអនុវត្តចំណាយវិនិយោគប្រចាំឆ្នាំ ២០១៣ រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានថវិកា-នាយកដ្ឋានថវិកានីយកម្ម- នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ) ឱ្យបានមុនថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ជាកំហិត។

ក្រសួងស្ថាប័នរដ្ឋបាលកណ្ដាល មន្ទីរជំនាញរាជធានី ខេត្តនិងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវរៀបចំរបាយការណ៍បូកសរុបអនុវត្តថវិការបស់ខ្លួនទៅតាមតារាងគំរូដែលមានភ្ជាប់មកជាមួយនេះ រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានតាមកាលកំណត់ខាងលើជាកំហិតដើម្បីឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារ

ជាតិ) មានលទ្ធភាពធ្វើការបូកសរុបរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច និងស្ថាប័ននីតិបញ្ញត្តិអនុម័តឱ្យបានទាន់ពេលវេលា។

ក្នុងករណីក្រសួងស្ថាប័នរដ្ឋបាលកណ្តាល មន្ទីរជំនាញរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុណា ផ្ញើរបាយការណ៍បូកសរុបទូទាត់របស់ខ្លួនមិនបានទាន់ពេលវេលាកំណត់ខាងលើទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងយកតួលេខរបាយការណ៍បូកសរុបរបស់អគ្គនាយកដ្ឋានរតនាគារជាតិធ្វើជាតួលេខផ្លូវការ។

គ្រប់ក្រសួងស្ថាប័នរដ្ឋបាលកណ្តាល អគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានីខេត្ត មន្ទីរជំនាញរាជធានីខេត្ត និងនាយកដ្ឋានពាក់ព័ន្ធទាំងឡាយត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន:**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អាជ្ញាធរសវនកម្មជាតិ

(ដើម្បីជូនជ្រាបជាព័ត៌មាន)

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

-គ្រប់ក្រសួងស្ថាប័នរដ្ឋបាលកណ្តាល

-អគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-រតនាគាររាជធានីខេត្ត

-គ្រប់មន្ទីរជំនាញតាមរាជធានីខេត្ត

(ដើម្បីអនុវត្ត)

-ឯកសារ -កាលប្បវត្តិ

ក្រសួង.......................

## តារាងសរុបចំណូលថវិកាថ្នាក់ជាតិ
## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣=២/១ | |
| | | | I- ផ្នែករដ្ឋបាលកណ្តាល<br><br>II- ផ្នែកមន្ទីរជំនាញរាជធានី ខេត្ត | | | | |
| | | | សរុបរួម | | | | |

| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខា | ហត្ថលេខា |
|---|---|---|---|
| អគ្គនាយករតនាគារជាតិ | រដ្ឋមន្ត្រី | ប្រធានគណនេយ្យ | អ្នកធ្វើតារាង |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួង......................

# តារាងសរុបចំណាយថវិកាថ្នាក់ជាតិ
## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ចលនាឥណទាន | | | | | ស្ថានភាពឥណទានថ្មី | អនុវត្តជាក់ស្តែង | ឥណទាននៅសល់ | សមាមាត្រប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | កើន | | | | ថយ | | | | | |
| | | | | | ចលនាផ្ទៃក្នុង | ឥណទានមិនបានគ្រោងទុក | បំពេញបន្ថែម | សរុប | | | | | | |
| | | | | ១ | ២ | ៣ | ៤ | ៥=២+៣+៤ | ៦ | ៧=១+៥-៦ | ៨ | ៩ = ៧ -៨ | ១០= ៨/៧ | ១១ |
| | | | **I. ផ្នែករដ្ឋបាលកណ្តាល** | | | | | | | | | | | |
| | | | ១-សរុបចំណាយចរន្ត | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | ២-សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | **II. ផ្នែកមន្ទីរជំនាញរាជធានីខេត្ត** | | | | | | | | | | | |
| | | | ១-សរុបចំណាយចរន្ត | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | ២-សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | សរុបរួម | | | | | | | | | | | |
| | | | ១-សរុបចំណាយចរន្ត<br>២-សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខា | ហត្ថលេខា |
| អគ្គនាយកឋានរតនាគារជាតិ | រដ្ឋមន្ត្រី | ប្រធានគណនេយ្យ | អ្នកធ្វើតារាង |

ក្រសួង......................

## តារាងសរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស
## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣

ឯកតា៖ ពាន់ដុល្លាអាមេរិក

| លេខគម្រោង | ឈ្មោះគម្រោង | ប្រភពជំនួយ | ប្រភេទជំនួយ | រយៈពេលអនុវត្តគម្រោង | តំលៃគម្រោង | គម្រោង ឆ្នាំ ២០១៣ | អនុវត្តជាក់ស្តែង ឆ្នាំ ២០១៣ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| សរុបរួម | | | | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខា | ហត្ថលេខា |
| អគ្គនាយកដ្ឋានរតនាគារជាតិ | រដ្ឋមន្ត្រី | ប្រធានគណនេយ្យ | អ្នកធ្វើតារាង |

**រាជធានី ខេត្ត.............**

**មន្ទីរ............................**

## តារាងសរុបចំណូលថវិកាថ្នាក់ជាតិ
## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ដើមឆ្នាំ | អនុវត្តជាក់ស្តែង | សមាមាត្រ ប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣=២/១ | |
| | | | | | | | |
| | | | សរុបរួម | | | | |

| | | | | |
|---|---|---|---|---|
| ហត្ថលេខានិងត្រា<br>ប្រធានរតនាគារ<br>រាជធានី ខេត្ត | ហត្ថលេខានិងត្រា<br>អភិបាលរាជធានី ខេត្ត | ហត្ថលេខានិងត្រា<br>ប្រធានមន្ទីរសេដ្ឋកិច្ច<br>និងហិរញ្ញវត្ថុ | ហត្ថលេខានិងត្រា<br>ប្រធានមន្ទីរ | ហត្ថលេខា<br>អ្នកធ្វើតារាង |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត......................
មន្ទីរ.....................................

## តារាងសរុបចំណាយថវិកាថ្នាក់ជាតិ
## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ចលនាឥណទាន | | | | | ស្ថានភាពឥណទានថ្មី | អនុវត្ត ជាក់ស្តែង | ឥណទាននៅសល់ | សមាមាត្រប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | កើន | | | | ថយ | | | | | |
| | | | | | ចលនាផ្ទៃក្នុង | ឥណទានមិនបានគ្រោងទុក | បំពេញបន្ថែម | សរុប | | | | | | |
| | | | | ១ | ២ | ៣ | ៤ | ៥=២+៣+៤ | ៦ | ៧=១+៥-៦ | ៨ | ៩ = ៧ -៨ | ១០= ៨/៧ | ១១ |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |

| | | | | |
|---|---|---|---|---|
| ហត្ថលេខានិងត្រា<br>ប្រធានរតនាគារ<br>រាជធានី ខេត្ត | ហត្ថលេខានិងត្រា<br>អភិបាលរាជធានី ខេត្ត | ហត្ថលេខានិងត្រា<br>ប្រធានមន្ទីរសេដ្ឋកិច្ច<br>និងហិរញ្ញវត្ថុ | ហត្ថលេខានិងត្រា<br>ប្រធានមន្ទីរ | ហត្ថលេខា<br>អ្នកធ្វើតារាង |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
Ministry of Industry, Mines and Energy
លេខ: ១០៤៣ [illegible]

# ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២០៧/១២ម.គ.ស.ព ចុះថ្ងៃទី២៣.០៣.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ្វីលីស៊ីធី ហ្គាមេន (ខេមបូឌា) ខបភើរេសិន ចុះថ្ងៃទី១៦.១០.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ហ្វីលីស៊ីធី ហ្គាមេន (ខេមបូឌា) ខបភើរេសិន (FELICITY GARMENT (CAMBODIA) CORPORATION LTD.) តំណាងដោយ លោក TSENG, WEN-HSIANG សញ្ជាតិចិន(តៃវ៉ាន់) អាយុ៤០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 303289204 ចុះថ្ងៃទី២៨.០៦.២០១១ មានអាសយដ្ឋានបច្ចុប្បន្នៈ Rm6, 11F., No.2, Jian 8th Rd, Zhonghe Dist., New Taipei City235, Taiwan(R.O.C). ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាផលិតផលខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកាត់ដេរសម្លៀកបំពាក់ ហ្វីលីស៊ីធី ហ្គាមេន (ខេមបូឌា) ខបភើរេសិន "*

**ទីតាំងរោងចក្រ៖** *" តំបន់សេដ្ឋកិច្ចពិសេសមេនហាតធេនស្វាយរៀង សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញនៅមុខរោងចក្រ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានសញ្ញាសម្គាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមប្រកាសប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០១៣

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**រដ្ឋលេខាធិការ**

**ឡាយ ណាវីន**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តស្វាយរៀង

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ១០៤៤ ឧរថ.កស-ព្រក

# ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ១០២៨/១២ម.គ.ស.ព ចុះថ្ងៃទី២០.១២.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អង្គរ ស្ព្រីង ចុះថ្ងៃទី១០.០៧.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន អង្គរ ស្ព្រីង (ANGKOR SPRING CO., LTD.) តំណាងដោយលោក NGUYEN KIM QUANG សញ្ជាតិវៀតណាម អាយុ៥២ឆ្នាំ កាន់លិខិតឆ្លងដែនលេខN1487000 ចុះថ្ងៃទី២២.០៣.២០១២ មានអាសយដ្ឋានបច្ចុប្បន្ន៖25 Duy Tan Ward 17 Phu Nhuan District, HCM Vietnam. ធ្វើការបង្កើតសាខារោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev4 Code |
|---|---|
| ទម្រពូករីស័រ | ៣១០០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រផលិត ឆ្អឹងពូករឺស័រ អង្គរ ស្ព្រីង (សាខាទី១) "*

**ទីតាំងរោងចក្រ ៖** *" តំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន ស្វាយរៀង សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរ [illegible] និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើល [illegible] ពីមុខរោងចក្រ ។/.

**<u>ប្រការ៧:</u>** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**<u>ប្រការ៨:</u>** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**<u>ប្រការ៩:</u>** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**<u>ប្រការ១០:</u>** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីប្រើតស៊ីល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានទាន់ពេលវេលា អំពីករណីប្រែប្រួលធំៗ ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០១៣

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**រដ្ឋលេខាធិការ**

**ឡាយ ណាវីន**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តស្វាយរៀង
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ១០៤៤ [illegible]

# ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២៤២២/១៣ គ.វ.ក ចុះថ្ងៃទី១៦.១០.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ៧រីវើរ ខនគ្រីត ខូ អិលធីឌី ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ៧រីវើរ ខនគ្រីត ខូ អិលធីឌី (7RIVER CONCRETE CO., LTD.) តំណាងដោយ លោក ឯម សុខជឿន សញ្ជាតិខ្មែរ អាយុ៣៣ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ 010004720 ចុះថ្ងៃទី០៥.១១.២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ លេខ១៦៨ ផ្លូវលេខ៤៦៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev 4 Code |
|---|---|
| ល្បាយពីបេតុង និងផលិតផលពីបេតុង | ២៣៩៥ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

**-ផ្លាកឈ្មោះរោងចក្រ ៖** *"រោងចក្រផលិតលូ និងផលិតផលធ្វើពីបេតុង ៧វីវើរ ខនគ្រីត ខូអិលធីឌី "*

**- ទីតាំងរោងចក្រ ៖** *"ភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។/ ៗ

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់ សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០ ១៣

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**រដ្ឋលេខាធិការ**

**ឡាយ ណាទីន**

ចម្លងជូន:

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តកណ្តាល

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤„ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ១០[illegible]

# ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ០៨២/១២ ក.អ.ក ចុះថ្ងៃទី១៣.០១.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អេសអេសខប (ខេមបូឌា) អិលធីឌី ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន អេសអេសខប (ខេមបូឌា) អិលធីឌី (SSCORP (CAMBODIA) LTD.) តំណាងដោយ លោក PHONGPAT VANICHJAKVONG សញ្ជាតិថៃ អាយុ៤០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ0479079 ចុះថ្ងៃទី១១.១២.២០១២ មានអាសយដ្ឋានបច្ចុប្បន្ន: 5/61 Soi Suanplu Thungmahamek Sathorn Bangkok, Thailand. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| អង្ករ | ១០៦១ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

**-ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកិនស្រូវ អេស អេស ខប (ខេមបូឌា) អិលធីឌី "*
**- ទីតាំងរោងចក្រ ៖** *" ផ្លូវជាតិលេខ៥ ភូមិល្វ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។ ៗល៕

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។/.

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ២០១៣

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**រដ្ឋលេខាធិការ**

**ឡាយ ណាទីន**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤,, "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ